**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**
លេខ....៣០៦៥/១៧ ស៨៣

កំពង់ធំ ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិក សម្រាប់អនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំ ជំណាក់កាលទី២ ( ផអ៣ទី២ ) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងខេត្តកំពង់ធំ

រដ្ឋបាលខេត្តកំពង់ធំ មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាជាមន្ត្រីរាជការ និងសាធារណៈជនទាំងអស់ឲ្យបានជ្រាបថា៖ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវការជ្រើសរើសបុគ្គលិកមួយចំនួន ដើម្បីបំរើការងារក្នុងកម្មវិធីផអ៣ទី២ នៅក្នុងខេត្តកំពង់ធំមានដូចខាងក្រោម៖

| ល.រ | មុខតំណែង | ចំនួន | ទីកន្លែង | ប្រាក់ខែ(ដុល្លារ) |
|---|---|---|---|---|
| ១ | បុគ្គលិកគាំទ្របច្ចេកទេសស្រុក | ០១ | -ស្រុកសន្ទុក ( ១ដំណែង ) | ២៥០ |

ក. តួនាទីភារៈកិច្ច នៃមុខតំណែងនេះមានដូចខាងក្រោម៖

១. បុគ្គលិកគាំទ្របច្ចេកទេសស្រុក

ជួយគាំទ្រដល់រដ្ឋបាលស្រុក ជាពិសេសការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ដើម្បីគាំទ្រជាចម្បងទាំងថ្នាក់ស្រុក និងឃុំសង្កាត់ ក្នុងការរៀបចំដំណើរការកសាងផែនការក្នុងការសិក្សាលទ្ធភាព គ្រប់គ្រង អនុវត្ត ត្រួតពិនិត្យគម្រោង និងក្នុងការគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យា និងជួយដល់ការិយាល័យពាក់ព័ន្ធទាំងឡាយក្នុងការអនុវត្តមុខងារដែលបានផ្ទេរឲ្យរដ្ឋបាលក្រុងស្រុក។

ខ. លក្ខណៈសម្បត្តិ និងបទពិសោធន៍ការងារ

១. បុគ្គលិកគាំទ្របច្ចេកទេសស្រុក

- បញ្ចប់បរិញ្ញាប័ត្រផង ក្នុងវិស័យអភិវឌ្ឍន៍ជនបទ កសិកម្ម បរិស្ថាន មុខងារសាធារណៈការគ្រប់គ្រងធុរៈកិច្ច ច្បាប់ និងសេដ្ឋកិច្ចជាដើម( សញ្ញាប័ត្រមានកម្រិតលើសពីនេះ កាន់តែល្អប្រសើរ ) និងមានបទពិសោធន៍យ៉ាងតិច ៣ ឆ្នាំទាក់ទងនឹងមុខតំណែងខាងលើ។
- មានការយល់ដឹងអំពីអភិបាលកិច្ច និងដំណើរការកសាងផែនការថ្នាក់ក្រុង ស្រុក និងឃុំសង្កាត់។
- មានបទពិសោធន៍ក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដូចជា ការបណ្តុះបណ្តាល ការសម្របសម្រួលសិក្ខាសាលា និងរៀបចំរបាយការណ៍បណ្តុះបណ្តាល។
- មានការយល់ដឹងច្បាស់អំពីការរៀបចំ និងគ្រប់គ្រងគម្រោងសំណើ ការអនុវត្ត ការតាមដាន និងរៀបចំរបាយការណ៍ ជាពិសេសគម្រោងមូលនិធិក្រុង ស្រុក និងឃុំសង្កាត់។
- មានការយល់ដឹងផ្នែកគ្រប់គ្រងកិច្ចការរដ្ឋបាល និងសារពើភ័ណ្ឌទ្រព្យសម្បត្តិ។
- មានចំណេះដឹង និងជំនាញកុំព្យូទ័រ ( Ms. Office, Internet and Email ) ។
- មានបទពិសោធន៍ក្នុងការបញ្ចូល និងគ្រប់គ្រងបណ្តាញ និងទិន្នន័យ។ ថែទាំ និងជួសជុលកុំព្យូទ័រ ( ផ្នែករឹង និងផ្នែកទន់ ) និងដោះស្រាយបញ្ហាដែលជួបប្រទះក្នុងការប្រើប្រាស់កុំព្យូទ័រ ( ជាការប្រសើរ )។
- ចេះភាសាខ្មែរច្បាស់លាស់ និងមានចំណេះដឹងភាសាអង់គ្លេសសម្រាប់បំពេញការងារ។

- មានអាសយដ្ឋានក្នុងក្រុង ស្រុក គោលដៅជាការប្រសើរ។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវលម្អិត(TOR)នៃមុខតំណែងខាងលើ ព្រមទាំងពាក្យសុំបម្រើការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប អាចរកបាននៅសាលាខេត្ត សាលាស្រុក និងនៅលើគេហទំព័ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ឬទំនាក់ទំនងមកកាន់ទូរស័ព្ទលេខ ៖

| | | |
|---|---|---|
| លោក សួត ច័ន្ទតារា | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | ០៧៧ ៧១ ៣១ ៧១ |
| លោកស្រី ភឿន ធារី | ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក | ០១៧ ៩២ ១៨ ៣៥ |
| | | ០១៦ ៩២ ៤៧ ២០ |

តាមរយៈE- mail៖ phoeun.theary@kpt.ncdd.gov.kh ឬ theary.phoeun@gmail.com

*បេក្ខជន ដែលមានចំណាប់អារម្មណ៍ សូម ផ្ញើពាក្យសុំបម្រើការងារមកកាន់ការិយាល័យគ្រប់គ្រងបុគ្គលិក នៃរដ្ឋបាលខេត្តកំពង់ធំជារៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ ២០១៧ វេលាម៉ោង ៥ និង ៣០នាទីល្ងាច ។

មានតែបេក្ខជនដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខជនអាទិភាព(Shortlist)ប៉ុណ្ណោះ ដែលនឹងទទួលបានព័ត៌មានអំពីការជ្រើសរើស។ បេក្ខជនជាស្ត្រីត្រូវបានលើកទឹកចិត្តសម្រាប់មុខតំណែងនេះ។

<u>បញ្ជាក់</u>៖ មុខតំណែងនេះ ជាប្រភេទកិច្ចសន្យាការងារធ្វើការពេញម៉ោង។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិល នោះបេក្ខជនត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្សក្នុងរយៈពេលនៃការបំពេញការងារជាមួយកម្មវិធីជាតិ។

**អភិបាល**

**សុខ~ណុ**

**ចម្លងជូន ៖**

- លេខាធិការដ្ឋានគ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត
  -ដើម្បីជូនជ្រាប-
- រដ្ឋបាលស្រុកសន្ទុក
- ឯកសារ-កាលប្បវត្តិ